កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

0112

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ១៦២៤ "ជ"

ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩

-សំណុំរឿងរដ្ឋប្បវេណីលេខ: ១៤៦៧

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០១៩ វេលាម៉ោង៨ និង០០ នាទីព្រឹកនៅសាលសវនាការទី៥ លើសំណុំរឿងរដ្ឋប្បវេណីលេខ១៤៦៧ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក **សោ សុតា** ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោកស្រី **លន់ ស៊ីផូ** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ **ផ** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅស្នាក់សព្វថ្ងៃនៅផ្ទះលេខ រាជធានីភ្នំពេញ ។

ដោយមានលោកស្រី **ង៉េត សុគន្ធា** ជាមេធាវីតំណាងអាណត្តិឱ្យដើមចោទឈ្មោះ **ផ** ។

-ចុងចម្លើយឈ្មោះ **ច១** ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ និងប្រពន្ធឈ្មោះ **ច២** អាយុ៣៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះ រាជធានីភ្នំពេញ ។

## I. **អង្គហេតុ និងចំណុចវិវាទ**

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន២០,១០០$ (ពីរម៉ឺនមួយរយដុល្លារអាមេរិក) ។

-បង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់ចំនួន២%(ពីរភាគរយ)ក្នុង១ខែគិតពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃអនុវត្តសងគ្រប់ចំនួន ។

-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ពិន័យចំនួន ១០% (ដប់ភាគរយ) លើចំនួនទឹកប្រាក់ដែលបានរអាក់ខានបង់មកឱ្យខ្លួនគិតពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃអនុវត្តការសងប្រាក់គ្រប់ចំនួន ។

-បង្គាប់ឱ្យចុងចម្លើយសងសោហ៊ុយសេវាមេធាវីចំនួន៥,០០០$(ប្រាំពាន់ដុល្លារអាមេរិក) ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

-សុំឱ្យតុលាការប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី**

ឈ្មោះ **ច១** និងប្រពន្ធឈ្មោះ **ច២** បានខ្ចីប្រាក់ពីខ្លួនចំនួន៣លើក ដោយលើកទី១នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ បានខ្ចីខ្លួនចំនួន២,០០០$(ពីរពាន់ដុល្លារអាមេរិក) , លើកទី២ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ បានខ្ចីប្រាក់ពីខ្លួនចំនួន១១,០០០$(មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) និងលើកទី៣បានខ្ចីប្រាក់ពីខ្លួននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ចំនួន១១,០០០$ (មួយម៉ឺនមួយពាន់ដុល្លារអាមេរិក) ដែលសរុបទាំងបីលើកមានចំនួនប្រាក់ ២៤,០០០$ (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) និងយល់ព្រមបង់ការប្រាក់ចំនួន៥%ក្នុង១ខែ ។ ដើម្បីធានាបំណុលខាងលើចុងចម្លើយឈ្មោះ **ច១** និងប្រពន្ធឈ្មោះ **ច២** បានយកអចលនទ្រព្យរបស់ខ្លួនមកដាក់បញ្ចាំគីលនៅម្ចាស់មួយកន្លែងដែលមានទីតាំងស្ថិតនៅស្ថិតនៅផ្ទះលេខ រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់និងប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ចេញដោយអភិបាលខណ្ឌ ។ បន្ទាប់មកប្តីប្រពន្ធទាំងពីរនាក់បានសងប្រាក់ដើមមកខ្លួនបានចំនួន ៣,៩០០$(បីពាន់ប្រាំបួនរយដុល្លារអារិក) នៅខ្វះប្រាក់ដើមចំនួន២០,១០០$ (ពីរម៉ឺនមួយរយដុល្លារអាមេរិក) ទៀត

ដែលមិនទាន់សងប្រាក់មកឱ្យខ្លួននោះទេ ព្រមទាំងមិនបានបង់ការប្រាក់ឱ្យខ្លួនចាប់ពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ មកដល់បច្ចុប្បន្ននេះផងដែរ ។ ហើយនៅដើមខែកុម្ភៈ ឆ្នាំ២០១៩ ចុងចម្លើយបានសុំខ្ចីទ្រព្យដែលបានដាក់ធានានេះថាយកទៅបង្ហាញអ្នកទិញដីនេះរួចហើយ និងប្រគល់មកឱ្យខ្លួនវិញនៅពេលអ្នកទិញកក់ប្រាក់នោះគាត់បានសងប្រាក់ដើមមកឱ្យខ្លួន ប៉ុន្តែជាក់ស្តែងបែរជាចុងចម្លើយបានគេចវេសពីខ្លួនទោះបីជាខ្លួនបានព្យាយាមទាក់ទងទៅចុងចម្លើយច្រើនដងក៏ដោយក៏ពួកគាត់មិនព្រមចូលមកដោះស្រាយជាមួយខ្លួនឡើយ និងមិនអាចធ្វើការទំនាក់ទំនងបានទេដោយចុងចម្លើយបានគេចវេសមិនព្រមអនុវត្តតាមកិច្ចសន្យានោះទេ ។

**៣.អង្គហេតុដែលអះអាងដោយដើមចោទ៖**

-ដើមចោទឈ្មោះ **ដ** ដោយមានលោកស្រី ង៉ែត សុគន្ធា ជាមេធាវីតំណាងអាណត្តិធ្វើសេចក្តីថ្លែងការណ៍ថា: នាងខ្ញុំសុំរក្សាពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ទុកនៅដដែលនឹងសុំបន្ថែមត្រង់ចំណុចទី៦ ដោយហេតុថាចុងចម្លើយបានខ្ចីប្រាក់ពីកូនក្តីនាងខ្ញុំសរុបជាទឹកប្រាក់ ២៤,០០០$ (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) ក្រោយមកចុងចម្លើយបានសងប្រាក់មកកូនក្តីនាងខ្ញុំបានចំនួន៣,៩០០$(បីពាន់ប្រាំបួនរយដុល្លារអាមេរិក) នៅសល់ប្រាក់ដើមចំនួន ២០,១០០$ (ពីរម៉ឺនមួយរយដុល្លារអាមេរិក) រហូតមកដល់សព្វថ្ងៃនេះចុងចម្លើយមិនបានសងប្រាក់មកខាងកូនក្តីខ្ញុំនោះទេ ។

និងស្នើសុំឱ្យតុលាការអនុវត្តជាបណ្តោះអាសន្នចំពោះប្រាក់ដើម ។

**៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ៖**

-ចុងចម្លើយឈ្មោះ **ច១** ធ្វើសេចក្តីថ្លែងការណ៍ថា: ខ្ញុំពិតជាបានខ្ចីប្រាក់ពីដើមចោទចំនួន២,០០០$ ពិតមែនប៉ុន្តែប្រាក់នេះខ្ញុំបានសងគ្រប់ចំនួនរួចហើយ គឺប្រពន្ធជាអ្នកសងគឺកិច្ចសន្យាចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ ។ ចំពោះកិច្ចសន្យាចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ និងកិច្ចសន្យាចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់ចំនួន ២២,០០០$ (ពីរម៉ឺនពីរពាន់ដុល្លារអាមេរិក) គឺខ្ញុំមិនទទួលខុសត្រូវឡើយដោយមិនបានដឹងលឺ ។ សរុបសេចក្តីមករាល់ការទាមទាររបស់ដើមចោទទាំង៦ចំណុចកន្លងមកខ្ញុំមិនទទួលស្គាល់ឡើយ ។

**៥.ចំណុចគ្មានវិវាទ**

(គ្មាន)

**៦.ចំណុចវិវាទ**

ចុងចម្លើយមិនទទួលស្គាល់ចំពោះការទាមទាររបស់ដើមចោទឡើយ ។

## II.ការពិនិត្យភស្តុតាង

**១ .ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.ឯកសារ ៖ កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ ។

១.២.ឯកសារ ៖ កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ។

១.៣.ឯកសារ ៖ កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ។

**២ .ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

(គ្មាន)

៣ .ការសាកសួរសាក្សី

(គ្មាន)

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់និងការពិនិត្យភស្តុតាងតុលាការយល់ឃើញថា៖

១-តាមពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ **ដ** ដោយមានលោកស្រី ង៉ែត សុគន្ធា ជាមេធាវីតំណាងដោយអាណត្តិ ធ្វើឡើងស្របច្បាប់តុលាការអាចលើកយកមកពិចារណាបាន ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

២-តាមការអះអាងរបស់ដើមចោទឈ្មោះ **ក** ដោយមានលោកស្រ **ង៉េត សុគន្ធា** ជាមេធាវីតំណាងអាណត្តិធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនសុំរក្សាពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ទុកនៅដដែលនិងសុំបន្ថែមត្រង់ចំណុចទី៦ ដោយហេតុថាចុងចម្លើយបានខ្ចីប្រាក់ពីកូនក្តីខ្លួនសរុបជាទឹកប្រាក់ ២៤,០០០$ (ពីរម៉ឺនបួនពាន់ដុល្លារអាមេរិក) ក្រោយមកចុងចម្លើយបានសងប្រាក់មកកូនក្តីខ្លួនបានចំនួន៣,៩០០$ (បីពាន់ដុល្លារអាមេរិក) នៅសល់ប្រាក់ដើមចំនួន២០,១០០$ (ពីរម៉ឺនមួយរយដុល្លារអាមេរិក) រហូតមកដល់សព្វថ្ងៃនេះចុងចម្លើយមិនបានសងប្រាក់មកខាងកូនក្តីខ្លួននោះទេ ។

៣-តាមការអះអាងចុងចម្លើយឈ្មោះ **ខ១** ធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនពិតជាខ្ចីប្រាក់ពីដើមចោទចំនួន២,០០០$ (ពីរពាន់ដុល្លារអាមេរិក) ពិតមែនប៉ុន្តែប្រាក់នេះខ្លួនបានសងគ្រប់ចំនួនរួចហើយ គឺប្រពន្ធជាអ្នកសងគឺកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ ។ ចំពោះកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់សរុបចំនួន ២២,០០០$ (ពីរម៉ឺនពីរពាន់ដុល្លារអាមេរិក) គឺខ្លួនមិនទទួលខុសត្រូវឡើយដោយមិនបានដឹងលឺ ។ សរុបសេចក្តីមករាល់ការទាមទាររបស់ដើមចោទទាំង៦ចំណុចកន្លងមកខ្លួនមិនទទួលស្គាល់ឡើយ ។

៤-ការទាមទាររបស់ដើមចោទមានភស្តុតាងច្បាស់លាស់គឺកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ខែមករាឆ្នាំ២០១៥ ,កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ។

៥-នៅពេលទាញហេតុផលដោយផ្ទាល់មាត់ចុងចម្លើយបានឆ្លើយបដិសេធថា ខ្លួនមិនទទួលខុសត្រូវចំពោះចំពោះកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់សរុបចំនួន ២២,០០០$ (ពីរម៉ឺនពីរពាន់ដុល្លារអាមេរិក) ខ្លួនមិនទទួលខុសត្រូវឡើយដោយខ្លួនមិនបានដឹងលឺ ចម្លើយនេះគឺជាចម្លើយដោះសាររបស់ចុងចម្លើយដើម្បីឆ្លើយយករួចខ្លួនតែប៉ុណ្ណោះ ។

៦-ផ្អែកតាមមាត្រា៥៧៨ និងមាត្រា៥៩១ នៃក្រមរដ្ឋប្បវេណីគឺអ្នកខ្ចីប្រាក់ឈ្មោះ **ខ១** និងប្រពន្ធឈ្មោះ **ខ២** មានករណីកិច្ចសងទៅសងប្រាក់ទៅឱ្យអ្នកខ្ចីវិញនូវប្រាក់ដើម និងការប្រាក់គ្រប់ចំនួនឱ្យទៅភាគីដើមចោទឈ្មោះ **ក** ។ ហេតុនេះគប្បីឱ្យចុងចម្លើយឈ្មោះ **ខ១** និងប្រពន្ធឈ្មោះ **ខ២** រួមគ្នាសងប្រាក់ដើមដែលនៅសេសសល់ចំនួន២០,១០០$ (ពីរម៉ឺនមួយរយដុល្លារអាមេរិក) ឱ្យទៅដើមចោទឈ្មោះ **ក** ។

៧-ដើមចោទបានប្តឹងសុំទាមទារការប្រាក់ ២%(ពីរភាគរយ)ក្នុង១ខែ គឺភាគីចុងចម្លើយមានករណីកិច្ចសងប្រាក់ដើមចំនួន ២០,១០០$(ពីរម៉ឺនមួយរយដុល្លារអាមេរិក) ឱ្យទៅដើមចោទវិញ ប៉ុន្តែការប្រាក់ចំនួន២%ក្នុង១ខែឃើញថាមានចំនួនការប្រាក់លើសច្បាប់កំណត់ ផ្អែកតាមមាត្រា៥៨៤,៥៩១ នៃក្រមរដ្ឋប្បវេណី និងលិខិតលេខ ១២៨ កយ-ប្រក/១១ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌ បានកំណត់អត្រាការប្រាក់មិនឱ្យលើសពី ១,៥%(មួយក្បៀសប្រាំភាគរយ) ក្នុងមួយខែលើប្រាក់ដើមចំនួន២០,១០០$(ពីរមួយរយដុល្លារអាមេរិក) ដោយគិតចាប់ពីថ្ងៃខកខានសងតាមកិច្ចសន្យាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ។

៨-ចំពោះប្រាក់ពិន័យចំនួន១០%(ដប់ភាគរយ)ក្នុង១ឆ្នាំលើចំនួនទឹកប្រាក់២០,១០០$ (ពីរមួយរយដុល្លារអាមេរិក) ដែលរាក់ខាងបង់ដោយគិតចាប់ពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ គប្បីតុលាការមិនលើកយកមកពិចារណា ។

៩-ដើមចោទបានស្នើសុំឱ្យតុលាការសម្រេចអនុវត្តបណ្តោះអាសន្នតុលាការមិនគប្បីមិនពិចារណាឡើយ។

១០-ចំពោះការទាមទារប្រាក់ថ្លៃសោហ៊ុយមេធាវី និងជម្ងឺចិត្តចំនួន៥,០០០$(ប្រាំពាន់ដុល្លារអាមេរិក) គប្បីតុលាការពិចារណា ។

១១-ប្រាក់ប្រដាប់ក្តីផ្អែកតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីគប្បីឱ្យចុងចម្លើយជាអ្នកទទួលបន្ទុក។

## សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឱ្យចុងចម្លើយ **ខ១** និងប្រពន្ធឈ្មោះ **ខ២** សងប្រាក់ទៅដើមចោទឈ្មោះ **ក** ដោយមានលោកស្រី **ង៉េត សុគន្ធា** ជាមេធាវីតំណាងអាណត្តិ នូវ ៖

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគំរូទេ

ក-ប្រាក់ដើមចំនួន **២០,១០០$** (ពីរម៉ឺនមួយរយដុល្លារអាមេរិក) ។

ខ-ការប្រាក់១,៥% ក្នុង១ខែ (មួយក្បៀសប្រាំភាគរយក្នុងមួយខែ) លើប្រាក់ដើមចំនួន **២០,១០០$** (ពីរម៉ឺនមួយរយដុល្លារអាមេរិក) គិតចាប់ពីថ្ងៃខកខានបង់រហូតដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ។

២-បង្គាប់ឲ្យចុងចម្លើយ **១១** និងប្រពន្ធឈ្មោះ **១២** សងប្រាក់ជម្ងឺចិត្ត និងនឹងសោហ៊ុយផ្សេងៗទៅដើមចោទឈ្មោះ **ខ** ចំនួន៥,០០០,០០០រៀល(ប្រាំលានរៀល) ទាមទារលើសពីនេះបដិសេធន៍ចោល ។

៣-ច្រានចោលប្រាក់ពិន័យចំនួន ១០%(ដប់ភាគរយ) ក្នុង១ឆ្នាំ លើចំនួនទឹកប្រាក់ ២០,១០០$ (ពីរម៉ឺនមួយរយដុល្លារអាមេរិក) ។

៤-ច្រានចោលអនុវត្តជាបណ្ដោះអាសន្ន ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទីនៅថ្ងៃទី**០៩ ខែធ្នូ ឆ្នាំ២០១៩** ចំពោះមុខគូភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី ប្រកាសជាសាធារណៈនៅថ្ងៃទី**២៥ ខែធ្នូ ឆ្នាំ២០១៩** ។

គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ (មួយ) ខែគិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

**សោ សុភា**

---

បានឃើញ

ចៅក្រមជំនុំជម្រះ

សោ សុភា

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃពុធ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩

ក្រឡាបញ្ជី

លន់_ស៊ីផូ